# តើ ChorogUsan ឈរអ៊ូសាន មានន័យដូចម្តេច?



ChorogUsan ឈរអ៊ូសាន មានន័យថា **"ឆត្របៃតង"** នៅក្នុងភាសាកូរ៉េ ដែលជានិមិត្តរូបនៃការអភិវឌ្ឍ ការការពារ និងក្តីសង្ឃឹមសម្រាប់កុមារគ្រប់រូប ដែលនេះប្រៀបទៅនឹងឆត្របៃតងដែលផ្តល់ជម្រកដល់កុមារ និងជួយឱ្យពួកគេអាចអភិវឌ្ឍបាន។ អង្គការឈរអ៊ូសានសម្រាប់កុមារ តែងតែឈរជាមួយកុមារដើម្បីការពារសិទ្ធិ និងធ្វើឱ្យពួកគេទទួលបានសុភមង្គល។

## ចក្ខុវិស័យ

បង្កើតពិភពលោកមួយដែលកុមារមានភាពរីករាយ

## បេសកកម្ម

អង្គការដែលធ្វើឱ្យកុមារទទួលបានសុភមង្គល

## ពាក្យស្លោក

តែងតែនៅជាមួយកុមារជានិច្ច



**អាទិភាពកុមារ**

គិតគូរដល់កុមារជាចម្បង និងធ្វើឱ្យពួកគេក្លាយជាបុគ្គលដែលអាចសម្រេចចិត្ត និងដឹកនាំខ្លួនឯងបាន

**សុចរិតភាព**

ស្វែងយល់ពីបញ្ហាដែលកុមារជួបប្រទះពិតប្រាកដ និងអនុវត្តការងារប្រកបដោយតម្លាភាព និងទំនុកចិត្ត

**ជំនាញ**

ប្រើប្រាស់ជំនាញវិជ្ជាជីវៈដើម្បីឱ្យសុខុមាលភាពកុមារមានភាពប្រសើរឡើង

**ស្មារតីការងារ**

កំណត់បញ្ហាថ្មីៗដោយយកចិត្តទុកដាក់ និងស្វែងរកដំណោះស្រាយផ្សេងៗប្រកបដោយប្រសិទ្ធភាព


**អាសយដ្ឋាន៖** ជាន់ទី៧ អគារ Amass Central Tower
ផ្ទះលេខ១៧៦ ផ្លូវ៦៣ បឹងកេងកងទី១ រាជធានីភ្នំពេញ

**ទូរសព្ទទំនាក់ទំនង៖** +855 (0) 23 902 105
**គេហទំព័រ៖** www.chorogusan.org.kh


ChorogUsan
for children | CAMBODIA



# តែងតែនៅជាមួយកុមារជានិច្ច

# វិស័យគម្រោងកម្មវិធី

### កិច្ចការពារកុមារ
ស្វែងរកមតិគាំទ្រដើម្បីបង្កើតបរិយាកាសដែលមានសុវត្ថិភាពសម្រាប់កុមារនិងលើកកម្ពស់សិទ្ធកុមារតាមរយៈការផ្លាស់ប្តូរវិយោបទសង្គម។

### ការអប់រំ
លើកកម្ពស់គុណភាពអប់រំ និងសមត្ថភាពឌីជីថល តាមរយៈការពង្រឹងសមត្ថភាពអ្នកអប់រំ ដើម្បីឱ្យកុមារត្រៀមខ្លួនបានល្អប្រសើរនាពេលអនាគតសម្រាប់ការរស់នៅក្នុងសង្គម។

### សុខភាព
លើកកម្ពស់សុខុមាលភាពមាតានិងទារក កុមារក្នុងវ័យលូតលាស់ តាមរយៈការគាំទ្រអាហារូបត្ថម្ភ ការបណ្តុះបណ្តាលក្នុងសហគមន៍ និងការកសាងសមត្ថភាពអ្នកផ្តល់សេវាសុខភាព។

### ទឹកស្អាត និងអនាម័យ
ធ្វើឱ្យប្រសើរឡើងសុខភាពសហគមន៍ ដោយពង្រឹងការទទួលបានទឹកស្អាត និងអនាម័យ ព្រមទាំងវគ្គបណ្តុះបណ្តាលស្តីពីការថែទាំសម្ភារៈហេដ្ឋារចនាសម្ព័ន្ធ និងការអនុវត្តអនាម័យផ្ទាល់ខ្លួន។

### ជីវភាពរស់នៅ
បង្កើនឱកាសសេដ្ឋកិច្ចប្រកបដោយចីរភាពសម្រាប់យុវជន តាមរយៈការពង្រឹងជំនាញឌីជីថល វិជ្ជាជីវៈ និងភាពជាសហគ្រិន ដោយប្រើប្រាស់អភិក្រមប្រព័ន្ធអេកូឡូស៊ីដែលផ្តោតលើយុវជនជាស្នូល។

### ការអភិវឌ្ឍសហគមន៍
ផ្តល់អំណាចដល់សហគមន៍ក្នុងការកៀរគរធនធាន និងកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍបែបពហុវិស័យ ដើម្បីអភិវឌ្ឍសហគមន៍ឱ្យមានភាពប្រសើរឡើង។

### ជំនួយមនុស្សធម៌
សង្គ្រោះជីវិត និងការពារសេចក្តីថ្លៃថ្នូរ តាមរយៈជំនួយសង្គ្រោះបន្ទាន់ ការស្តារឡើងវិញ និងការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម ក្នុងអំឡុងពេលមានវិបត្តិ។



# គម្រោងបច្ចុប្បន្ន




### ០១. គម្រោងអភិវឌ្ឍន៍កុមារ តំបន់បឹងត្របែក
- គម្រោងនេះផ្តោតទៅលើការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ការកសាងទីកន្លែងសុវត្ថិភាពសម្រាប់គ្រួសារដែលមានជីវភាពខ្សត់ខ្សោយ ដែលរួមបញ្ចូលការថែទាំកុមារប្រកបដោយគុណភាព ការអប់រំ និងការពង្រឹងសមត្ថភាពអាណាព្យាបាលដើម្បីភាពធន់នៅក្នុងសហគមន៍។

### ០២. គម្រោងបង្កើនសមត្ថភាពឌីជីថលក្នុងវិស័យអប់រំ
- **ដៃគូ៖** អង្គការឆាលហ្វាន កម្ពុជា
- គម្រោងនេះផ្តោតទៅលើការបង្កើតបន្ទប់ឌីជីថលនៅក្នុងសាលារៀនចំនួន១៧ និងកម្មវិធីសិក្សាផ្នែកបច្ចេកវិទ្យាគមនាគមន៍ (ICT) ហិរញ្ញវត្ថុ និងសុវត្ថិភាពឌីជីថល ដែលត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ឱ្យសិស្សនូវជំនាញបច្ចេកវិទ្យាដ៏សំខាន់នៃសតវត្សរ៍ទី២១។

### ០៣. គម្រោងលើកកម្ពស់ការអប់រំឌីជីថលសម្រាប់សិស្សានុសិស្ស
- **ដៃគូ៖** អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា
- គម្រោងនេះបានប្រែក្លាយសាលារៀនចំនួន១២ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថលកម្រិតខ្ពស់ និងពង្រឹងអភិបាលកិច្ច ដើម្បីធានាបាននូវការទទួលបានបច្ចេកវិទ្យាសម្រាប់សិស្សានុសិស្សគ្រប់រូបប្រកបដោយសមធម៌។





### ០៤. គម្រោងលើកកម្ពស់សុខភាព និងសិទ្ធិរបស់យុវតី តាមរយៈធ្វើឱ្យប្រសើរឡើងនូវអនាម័យ និងការថែទាំខ្លួនពេលមានរដូវ
- **ដៃគូ៖** អង្គការថែទាំសុខភាពគ្រួសារកម្ពុជា
- គម្រោងនេះផ្តល់ការការពារសេចក្តីថ្លៃថ្នូរដល់យុវតី ដោយកែលម្អសម្ភារៈបរិក្ខារអនាម័យក្នុងសាលារៀន និងជំរុញការគាំទ្រពីសហគមន៍សម្រាប់ការគ្រប់គ្រងអនាម័យពេលមករដូវ។

### ០៥. គម្រោងអភិវឌ្ឍន៍យុវជន និងពង្រឹងសហគ្រិនភាពក្នុងវិស័យកសិកម្ម ដើម្បីលើកកម្ពស់ទីផ្សារ និងភាពរីកចម្រើនរបស់សហគមន៍
- **ម្ចាស់ជំនួយ៖** ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)
- **ដៃគូ៖** អង្គការ Wonders International
- គម្រោងនេះជំរុញភាពច្នៃប្រឌិតរបស់យុវជន ដោយផ្តល់ការបណ្តុះបណ្តាលការប្រឹក្សាយោបល់ និងមូលនិធិគាំទ្រអាជីវកម្ម ដើម្បីប្រែក្លាយគំនិតអាជីវកម្មក្នុងវិស័យកសិកម្មទៅជាអាជីវកម្មប្រកបដោយនិរន្តរភាព។

### ០៦. គម្រោងងាយស្រួលរៀន ដំណាក់កាលទី៣
- **ម្ចាស់ជំនួយ៖** ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)
- **ដៃគូ៖** អង្គការឆាលហ្វាន កម្ពុជា និងអង្គការកាហ្វដុក
- គម្រោងនេះលើកកម្ពស់គុណភាពការអប់រំកម្រិតបឋមសិក្សា ដោយធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការបង្រៀន និងបរិយាកាសសិក្សា ដើម្បីជំរុញប្រសិទ្ធភាពនៃការអាន និងគណិតវិទ្យានៅថ្នាក់ដំបូង។

